# ប្រាសាទដើមចន្ទន៍នៅសំបូរព្រៃគុក

ប្រាសាទដើមចន្ទន៍ ជាក្រុមប្រាសាទមួយដែលស្ថិតនៅក្នុងក្រុមប្រាសាទសំបូរ ឬក្រុមខាងជើង នៃតំបន់ប្រាសាទសំបូរព្រៃគុក ចុះបញ្ជីលេខ N15, N16-1, N16-2។ ប្រាសាទនេះ ស្ថិតនៅទិសខាងកើតប្រាសាទគុកវិហារ (N17) និងស្ថិតនៅទិសឦសានតួប៉មកណ្តាល (N1)។ ឈ្មោះ "ដើមចន្ទន៍" នេះ គឺជាឈ្មោះថ្មីដែលអ្នកស្រុកហៅ ព្រោះប្រាសាទនេះសព្វថ្ងៃនៅក្បែរដើមចន្ទន៍។ ចំណែកឯឈ្មោះដើមរបស់ប្រាសាទវិញ យើងមិនដឹងមានឈ្មោះអ្វីឱ្យប្រាកដឡើយ ព្រោះអត្ថបទសិលាចារឹកចំនួនមួយក្នុងចំណោមពីរផ្ទាំងដែលរកឃើញនៅទីនេះ បានរលុបអក្សរត្រង់ព្រះនាមរបស់សិវលិង្គ ឬឈ្មោះរបស់ប្រាសាទ។

ប្រាសាទដើមចន្ទន៍ កសាងឡើងអំពីឥដ្ឋ មានតួប៉មបីរត់ជួរគ្នាពីអ័ក្សជើងទៅត្បូងបែរមុខទៅទិសខាងកើត និងមានកំពែងឥដ្ឋហ៊ុមព័ទ្ធជុំវិញ។ តួប៉មកណ្តាល នៅមានរូបរាងល្អប្រសើរច្រើន និងតួប៉មពីរទៀតនៅសងខាង គឺទើបតែមានការធ្វើកំណាយនិងជួសជុលឡើងវិញដោយក្រុមការងារអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុកកាលពីឆ្នាំ២០២០ ហើយចំណែកឯកំពែងរបស់ប្រាសាទដែលស្ថិតនៅទួលក្បែរដើមចន្ទន៍ធ្លាប់មានការកំណាយម្តងកាលពីឆ្នាំ២០១៣ ក្នុងគម្រោងអភិរក្សប្រាសាទសំបូរព្រៃគុក ដឹកនាំដោយលោក ឈុំ ម៉េងហុង (រូបលេខ១-៤)។

តួប៉មកណ្តាល មានរាងបួនជ្រុងទ្រវែង ដែលខាងក្នុងមាននៅសល់បំណែកជើងទម្រថ្មភក់រាងបួនជ្រុងចំនួនមួយ តាមជញ្ជាំងមានរៀបជាថ្មភក់រាងដូចកំណាត់ឈើសម្រាប់ភ្ជាប់ធ្វើពិតាន និងផ្នែកខាងកើតគេតម្រៀបឥដ្ឋជារាងសាជីជ្រុងដើម្បីសម្រាលទម្ងន់ឥដ្ឋនៅខាងលើ។ តួប៉មនេះមានទ្វារចូលពីទិសខាងកើត និងមានទ្វារបញ្ឆោតនៅទិសបីផ្សេងទៀត។ ទ្វារបញ្ឆោតនីមួយៗសិល្បករឆ្លាក់ចេញជាសសរពេជ្ររាងមូល ផ្តែរទ្វារ និងក្បាច់ផ្សេងទៀតនៅលើទ្វារបញ្ឆោតដែលសុទ្ធសឹងធ្វើឡើងអំពីឥដ្ឋ ដែលជាលក្ខណៈពិសេសមួយដែលយើងមិនសូវឃើញមានច្រើនឡើយនៅសម័យមុនអង្គរ ព្រោះភាគច្រើនគេតែងធ្វើផ្តែរទ្វារអំពីថ្មភក់។ ហោជាង និងផ្តែរទ្វារនៅតាមទ្វារបញ្ឆោតរបស់តួប៉មនេះ នៅមានរូបរាងល្អណាស់ ដែលក្នុងហោជាងនីមួយៗច្រើនលម្អជាក្បាច់គូឌុមានព្រះសិវទេពនៅខាងក្នុង (រូបលេខ៥)។ ចំណែក ចម្លាក់វិមានអណ្តែតនៅតាមជញ្ជាំងវិញមានលក្ខណៈពិសេសៗជាងប្រាសាទផ្សេងៗទៀតច្រើនយ៉ាង។ ជាក់ស្តែង ចម្លាក់វិមានអណ្តែតនៅមុខខាងត្បូងផ្នែកខាងកើត យើងឃើញចម្លាក់នៅផ្នែកកណ្តាលមានរូបទ្វារបាលពីរពាក់មួករាងទ្រវែងស្រួចចុង និងមានរំយោលធ្លាក់មកចំហៀង ដែលលោក **ហេង ពិភាល់** យល់ថា គឺជាសិល្បៈដែលចេញពីប្រទេសពែរ្សបុរាណ (អាស៊ីកណ្តាល) ហើយអាចហូរចូលមកខ្មែរតាមរយៈអារ្យធម៌

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ឥណ្ឌា[១] (រូបលេខ២៦)។ ចម្លាក់វិមានអណ្ដែតមួយទៀតនៅមុខខាងលិចផ្នែកខាងជើងវិញ នៅផ្នែកកណ្ដាលក្នុងសសរផ្ដោបមានចម្លាក់មួយអង្គុយ ដាក់ជង្គង់ឡើងលើដៃកាន់ដំបង ដែលលោក **ចិន្ត ច័ន្ទរតនា** យល់ថា ជារូបភាពមួយរបស់ឥសីក្នុងលទ្ធិព្រាហ្មណ៍សាសនា[២] (រូបលេខ២៧)។ ជាងនេះទៅទៀត នៅផ្នែកខាងលើ តាមជ្រុងនីមួយៗមានលម្អជារូបគ្រុឌ អមដោយរូបសត្វហង្សនៅតម្រៀបគ្នា ក្នុងរូបភាពតំណាងឱ្យអំពីសត្វពិសិដ្ឋទ្រសំណង់ព្រះអាទិទេព (រូបលេខ២៨)។ ក្រៅពីចម្លាក់ទាំងអម្បាលម៉ាន នៅតួប៉មកណ្ដាលនេះ គេធ្លាប់រកឃើញផ្ដែរទ្វារមួយស្ថិតនៅក្នុងសិល្បៈរចនាបថសំបូរព្រៃគុកដែលមានប្រវែងបណ្ដោយ ១១៩ស.ម., ទទឹង ២៥,៥ស.ម. កម្ពស់ ៤៦ស.ម ដែលនៅចំកណ្ដាលមានឆ្លាក់រូបព្រះឥន្ទ្រ (អាទិទេពនៃភ្លៀង ផ្គរ រន្ទះ ជាស្ដេចនៅស្ថានសួគ៌ និងជាលោកបាលនៅទិសខាងកើត) គង់នៅលើសត្វដំរីឰរ៉ាវត៌ និងអមសងខាងដោយទេពមរុត (កងទ័ពខ្យល់របស់ព្រះឥន្ទ្រ) គង់នៅលើសត្វសេះ (រូបលេខ២៩)។

ចំណែក តួប៉មនៅសងខាងវិញ មានរាងបួនជ្រុងស្មើ និងទំហំតូចជាងតួប៉មកណ្ដាល ដែលហាក់ដូចជាមានតួនាទីជាសំណង់រណប។ ប្រការគួរកត់សម្គាល់ ក្នុងពេលធ្វើកំណាយដោយក្រុមការងារអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក កាលពីឆ្នាំ២០២០ គេបានរកឃើញថ្មភក់មួយស្រទាប់ដែលមានរាងមូល នៅខាងក្នុងតួប៉មខាងត្បូង។ ក្នុងន័យនេះ តួប៉មខាងជើងអាចទំនងជាតួប៉មដែលតម្កល់ព្រះព្រហ្ម ព្រោះជាទូទៅជើងទម្រព្រះព្រហ្មច្រើនតែមានរាងមូល ហើយបើជាសំណង់បីដូច្នេះច្រើនតែនៅទិសខាងត្បូងដូច្នេះដែរ ឧទាហរណ៍ ករណីប្រាសាទភ្នំក្រោម និងភ្នំបូក ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩-៩១០)។ ជាងនេះទៅទៀត សូម្បីតែនៅប្រាសាទស្រង់ព្រះ (តួប៉ម N22) ជាប្រាសាទតម្កល់ព្រះព្រហ្មដែលស្ថិតនៅទិសអាគ្នេយ៍តួប៉មប្រាសាទសំខាន់ N1 ក៏គេរកឃើញថ្មមួយស្រទាប់ខាងលើមានរាងមូលដូច្នេះដែរ។ ដូច្នេះ ប្រសិនបើតួប៉មខាងត្បូងនេះពិតជាសំណង់តម្កល់ព្រះព្រហ្មមែន ទំនងជាតួប៉មកណ្ដាលអាចតម្កល់សិវលិង្គ (តំណាងព្រះឥសូរ) និងតួប៉មខាងជើងអាចតម្កល់ព្រះវិស្ណុ ពោល គឺជារូបភាពមួយដែលគេតែងហៅថា "ត្រីមូត្តិ" មានន័យថាការបង្ហាញទេពបី (ព្រះព្រហ្ម ព្រះឥសូរ ព្រះវិស្ណុ) ដូចយើងធ្លាប់ឃើញមាននៅប្រាសាទភ្នំក្រោម និងភ្នំបូក ក្នុងស.វ.ទី៩ ដែរ។

ដូចពោលពីខាងលើមកស្រាប់ ប្រាសាទដើមចន្ទន៍គេធ្លាប់រកឃើញសិលាចារឹកចំនួនពីរផ្ទាំង ដែលចុះបញ្ជីលេខ K.148 (ចារឹកនៅស.វ.ទី១០) និងK.438 (ចារឹកនៅស.វ.ទី៧)។ សិលាចារឹក K.438

---

[១] ហេង ពិគាល់ ២០០៩: ៧៤។

[២] CHEN Chanratana 2005-2006: 232.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ចារឹកស.វ.ទី៧ ហើយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ ចារឹកជាភាសាសំស្ក្រឹតចំនួន១០បន្ទាត់ និងចារឹកជាភាសាខ្មែរចំនួន ១១បន្ទាត់ ដែលទំនងចារឹកឡើងក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧)។ ផ្នែកភាសាសំស្ក្រឹតខាងលើមានរលុបតួអក្សរច្រើន នាំឱ្យអ្នកស្រាវជ្រាវពិបាកក្នុងការប្រែអត្ថន័យ រីឯផ្នែកភាសាខ្មែរបុរាណមានភាពល្អប្រសើរច្រើន។ តួអក្សរផ្នែកភាសាសំស្ក្រឹតដែលនៅសល់រៀបរាប់អំពីព្រាហ្មណ៍ម្នាក់មកពីទីក្រុងទក្សិណាបថ នៃប្រទេសឥណ្ឌា មាននាមថា "**ទុគ្គស្វាមិ**" ហើយព្រាហ្មណ៍នេះបានរៀបអភិសេកជាមួយបុត្រីរបស់ព្រះបាទឦសានវរ្ម័នទី១។ នៅបន្ទាត់ទី៨ រៀបរាប់អំពីការកសាងសិវលិង្គ ប៉ុន្តែមិនដឹងព្រះនាមអ្វីឡើយ ដោយសារអក្សររលុបបាត់ទៅហើយ។ ចំណែកផ្នែកខាងក្រោមដែលចារឹកជាភាសាខ្មែររៀបរាប់អំពីព្រាហ្មណ៍ទុគ្គស្វាមិដែលស្តេចប្រទានងារជា "**ម្រតាញ**" (មន្ត្រីជាន់ខ្ពស់ក្នុងរាជការ) បានធ្វើអំណោយដល់អាទិទេពនៅស្រុកមួយ (រលុបអក្សរមិនស្គាល់ថាឈ្មោះស្រុកអ្វី) និងអំណោយរបស់មន្ត្រីម្នាក់ទៀតឈ្មោះ "**ម្រតាញពោះកំភោ**" ថ្វាយដល់ស្រុកតន្ទេញាលដងកំពង់ចំបក់ ដែលមានឈ្មោះថា "**សាលត្នះ**"។ អំណោយម្រតាញទុគ្គស្វាមិមានដូចជា គោ ក្របី ស្រែ ចំការ ថ្វាយចំពោះអាទិទេពព្រះនាម "**កម្រតេងអញស្រីប្រហសិតេស្វរ**" (Kamrateṅ aṅ Śrīprahasiteśvara) (អាទិទេពធំជាងគេនៅក្រុមប្រាសាទយាយព័ន្ធឬក្រុមខាងត្បូង)។ ចំណែកបន្ទាត់ចុងក្រោយ គេរៀបរាប់ថា ម្រតាញទុគ្គស្វាមិជាប្រធានក្រុមចាត់ចែងពិធីសាសនានៅសាលត្នះ នាក្រុងឦសានបុរ។[៣]

សិលាចារឹកមួយទៀត ចុះបញ្ជីលេខ K.148 ចារឹកនៅលើមេទ្វារខាងកើតផ្នែកខាងត្បូងនៃតួប៉មកណ្តាលប្រាសាទដើមចន្ទន៍ (រក្សាទុកនៅទីតាំងដើម) ចារឹកជាភាសាសំស្ក្រឹតមានចំនួន ២៨បន្ទាត់ (១៤ គាថា) ចារឹកឡើងនៅក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧) ស.វ.ទី១០។ សិលាចារឹកនេះរលុបអក្សរជាច្រើនកន្លែង ធ្វើឱ្យអ្នកស្រាវជ្រាវពិបាកក្នុងការប្រែអត្ថន័យដូចសិលាចារឹកខាងលើដែរ។ តួអក្សរដែលនៅសល់អាចឱ្យគេដឹងថា សិលាចារឹកនេះរៀបរាប់អំពីការគោរពព្រះអាទិទេពជាច្រើនមាន ព្រះឥសូរ (សម្ភុ) ព្រះវិស្ណុ (វាសុទេវាយ) ព្រះព្រហ្ម។ បន្ទាប់មកទៀត គេបានរៀបរាប់អំពីមន្ត្រីជាន់ខ្ពស់របស់ព្រះរាជាម្នាក់មាននាមថា "មង្គលាចារ្យ" បានសាងអាស្រមចំនួនមួយឈ្មោះថា "មង្គលអាស្រម" និងរៀបរាប់អំពីអាស្រមមួយទៀតឈ្មោះថា "រុទ្រអាស្រម" (អាស្រមព្រះឥសូរ)។ ព្រមទាំងរៀបរាប់អំពីការស្ថាបនារូបព្រះវិស្ណុក្នុងព្រះនាមថា "ឧទ្ធរ" និងករក

[៣] Cœdès 1952: 25.

សាងសិវលិង្គមួយឈ្មោះថា "ស្រីគម្ភីរេស្វរ" (Śrĭgambhĭreśvara) ដែលជាអាទិទេពដ៏សំខាន់នៅក្នុងក្រុមប្រាសាទសំបូរតែម្តង។[៦]

តាមអត្ថន័យសិលាចារឹក K.148 ដែលចារឹកឡើងនៅស.វ.ទី១០ នេះ នាំឱ្យយើងកាន់តែជឿថា តួប៉មខាងត្បូងទំនងជាតម្កល់ព្រះព្រហ្មមែន ហើយតួប៉មកណ្តាលជាព្រះឥសូរ (សម្ភុ) និងតួប៉មខាងជើងជាព្រះវិស្ណុ (វាសុទេវាយ) ព្រោះសេចក្តីនៃសិលាចារឹកបន្ទាប់ដំបូងៗបានរៀបរាប់អំពីការគោរពមកអាទិទេពទាំងបីនេះ (ត្រីមូត៌ិ)។ ជាងនេះទៅទៀត យើងអាចសន្និដ្ឋានបានថា តួប៉មកណ្តាលប្រាសាទដើមចន្ទន៍ ទំនងសាងឡើងនៅក្នុងស.វ.ទី៧ (រជ្ជកាលព្រះបាទឦសានវរ្ម័នទី១) ប៉ុន្តែនៅស.វ.ទី១០ គេបានមកចារសិលាចារឹកនៅលើមេទ្វាររបស់ប្រាសាទក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ហើយតួប៉មរណបដែលនៅសងខាងទំនងសាងឡើងនៅស.វ.ទី១០ (រជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន)។ ករណីនេះ វាដូចគ្នានឹងតួប៉មរណបទាំងបួនដែលនៅជុំវិញតួប៉មកណ្តាល N1 ពោល គឺតួប៉ម N2, N3, N4, N5 ដែលសុទ្ធសឹងជាសំណង់នៅស.វ.ទី១០ ដូចគ្នាដែរ។ ជាទូទៅសំណង់រណបនៅប្រាសាទដើមចន្ទន៍ និងនៅជុំវិញតួប៉មសំខាន់ N1 មានទំហំតូចៗប្រហាក់ប្រហែលគ្នា ហើយម្យ៉ាងវិញទៀត សូម្បីតែឥដ្ឋដែលគេយកមកប្រើប្រាស់ក៏មានលក្ខណៈតូចជាងនិងខុសពីឥដ្ឋដែលប្រើប្រាស់នៅស.វ.ទី៧ ដែរ។ លើសពីនេះទៀត នៅតួប៉ម N4 គេធ្លាប់រកឃើញផ្តែរទ្វារមួយដែលយកផ្តែរស.វ.ទី៧មកកាត់តម្រឹមឱ្យខ្លីប្រើប្រាស់ម្តងទៀតនៅស.វ.ទី១០ (រូបលេខ១០)។

ជារួមមក ប្រាសាទដើមចន្ទន៍ ទំនងជាសំណង់ដែលសាងឡើងដំបូងចំនួនមួយតួប៉ម (តួប៉មកណ្តាល) នៅស.វ.ទី៧ និងសង់បន្ថែមក្រោយចំនួនពីរតួប៉មទៀត (តួប៉មរណបសងខាង) ដើម្បីតម្កល់ព្រះអាទិទេពសំខាន់ៗចំនួនបីអង្គនៃលទ្ធិព្រហ្មញ្ញសាសនា គឺព្រះព្រហ្ម ព្រះឥសូរ និងព្រះវិស្ណុ។ សំណង់ចំនួនបីក្នុងទម្រង់ជាត្រីមូត៌ិទន្ទឹមគ្នារបៀបនេះនៅស.វ.ទី៧ គេមិននិយមឡើយ ដូចករណីប្រាសាទដើមចន្ទន៍នេះស្រាប់ គឺគេទើបនឹងបន្ថែមនៅស.វ.ទី១០ ប៉ុណ្ណោះ៕

[៦]Cœdès 1952: 33.



រូបលេខ១៖ ប្រាសាទដើមចន្ទន៍ (មើលពីទិសខាងកើត)



រូបលេខ២៖ ប្រាសាទដើមចន្ទន៍ (មើលពីទិសអាគ្នេយ៍)



រូបលេខ៣៖ ប្រាសាទដើមចន្ទន៍ (មើលពីទិសខាងត្បូង)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៤៖ ប្រាសាទដើមចន្ទន៍ (មើលពីទិសឦសាន)



រូបលេខ២៥៖ ហោជាងនិងផ្តែរទ្វារធ្វើអំពីឥដ្ឋនៃប្រាសាទដើមចន្ទន៍

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





*រូបលេខ២៦៖ ចម្លាក់រូបជនបរទេសនៅលើប្រាសាទអណ្តែតនៃប្រាសាទដើមចន្ទន៍(មុខខាងត្បូងផ្នែកខាងកើត)*





*រូបលេខ២៧៖ ចម្លាក់រូបឥសី(?)នៅលើប្រាសាទអណ្តែតប្រាសាទដើមចន្ទន៍ (មុខខាងលិចផ្នែកខាងជើង)*



*រូបលេខ៨៖ ចម្លាក់រូបគ្រុឌនៅជ្រុងអាគ្នេយ៍នៃប្រាសាទដើមចន្ទន៍*



*រូបលេខ៩៖ ផ្តែរទ្វារប្រាសាទដើមចន្ទន៍ (សារមន្ទីរខេត្តកំពង់ធំ)*



*រូបលេខ១០៖ ផ្តែរទ្វារដែលគេកាត់តម្រឹមឱ្យខ្វីនៅស.វ.ទី១០ នៅតួប៉មN4 (សាលពិពណ៌សំបូរព្រៃគុក)*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

*ហេង ពិភាល់*

*២០០៩, "ចម្លាក់រូបជនបរទេសនៅសម្បូណ៌ព្រៃគុក", កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ, លេខ ៤ ភ្នំពេញ*

**Chen, Chanratana**

2005-2006, "*Etudes des palais volants dans l'art khmer préangkorien*", Diplôme de Master de recherché, Histoire et Archéologie de l'Asie du Sud-est Année, Paris.

**Coedès, George**

1952, *Inscription du Cambodge*, Vol IV, Hanoi.